01008515

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**ឯកសារ A122/6.1/3**

សំណុំរឿងលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ០៩)

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន ប្រធាន**

**ចៅក្រម Rowan DOWNING**

**ចៅក្រម ន៉ិយ ថុល**

**ចៅក្រម Chang-Ho CHUNG**

**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤

---

**សម្ងាត់បំផុត**

**សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង**

---

**សហមេធាវីការពារក្តី អ៊ឹម ចែម**
ប៊ិត ស៊ាងលីម
John R.W.D. JONES

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
យូ ប៊ុនឡេង
Mark B. HARMON

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 15 / 08 / 2014
ម៉ោង (Time/Heure): 13:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

01008516



**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំឮ្យរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង" ដែលបានដាក់កាលពីថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ("សំណើសុំឮ្យរ")[1]។

## I. **សាវតារនីតិវិធី**

1. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ សហមេធាវីបានបញ្ជូនលិខិតមួយច្បាប់ជូនសហចៅក្រមស៊ើបអង្កេត ដោយបានស្នើសុំបញ្ចូលសហចៅក្រមស៊ើបអង្កេតទាំងពីររូបនៅក្នុងទំនាក់ទំនងទាំងអស់ជាផ្លូវការទាក់ទិននឹងអ្នកស្រី អ៊ឹម ចែម និងស្នើថា ការខ្វែងយោបល់គ្នាមួយចំនួនដែលទាក់ទិននឹងការកោះហៅ និងការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម គួរត្រូវបានបញ្ជូនទៅកាន់អង្គបុរេជំនុំជម្រះ[2]។ នៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតបានឆ្លើយតបរួមគ្នាថា "ការងារផ្ទៃក្នុងនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") គឺជាការសម្ងាត់" "តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចរបស់ចៅក្រមម្នាក់នៅក្នុងការបញ្ជូនការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះគឺជាឆន្ទានុសិទ្ធិ" និង "លើកលែងតែ និងរហូតដល់ពេលដែលការបញ្ជូនខាងលើនេះត្រូវបានធ្វើឡើង ខ្លឹមសារនៃសៀវភៅចុះបញ្ជីនៃការខ្វែងយោបល់គ្នានៅតែជាបញ្ហាផ្ទៃក្នុងនិងសម្ងាត់នៃ ក.ស.ច.ស"។ សហចៅក្រមស៊ើបអង្កេតបានបន្ថែមថា រយៈពេល ៣០ ថ្ងៃ ដែលបានកំណត់នៅក្នុងវិធាន ៧២(៣) នៃវិធានផ្ទៃក្នុង ក្នុងការនាំយកការខ្វែងយោបល់គ្នាដូចបានយោងនៅក្នុងលិខិតចុះថ្ងៃទី ១៣ ខែ មិថុនា ដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះបានកន្លងផុត "ដោយគ្មានការបញ្ជូនការខ្វែងយោបល់ណាមួយទៅអង្គបុរេជំនុំជម្រះនោះទេ"[3]។

---

[1] ឯកសារ A122/6.1/1។ សំណើសុំឮ្យរបានដាក់ជាភាសាខ្មែរនៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤។

[2] លិខិតមកពីសហមេធាវីផ្ញើជូនសហចៅក្រមស៊ើបអង្កេត កម្មវត្ថុ៖ "លិខិតស្នើសុំបញ្ចូលសហចៅក្រមស៊ើបអង្កេតទាំងពីររូបនៅក្នុងទំនាក់ទំនងទាំងអស់ជាផ្លូវការទាក់ទិននឹងអ្នកស្រី អ៊ឹម ចែម និងស្នើថា ការខ្វែងយោបល់គ្នាមួយចំនួនដែលទាក់ទិននឹងការកោះហៅ និងការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម គួរត្រូវបានបញ្ជូនទៅកាន់អង្គបុរេជំនុំជម្រះ" ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ A122។

[3] លិខិតមកពីសហចៅក្រមស៊ើបអង្កេតផ្ញើជូនសហមេធាវី កម្មវត្ថុ៖ "លិខិតរបស់លោកស្នើសុំបញ្ចូលសហចៅក្រមស៊ើបអង្កេតទាំងពីររូបនៅក្នុងទំនាក់ទំនងទាំងអស់ជាផ្លូវការទាក់ទិននឹងអ្នកស្រី អ៊ឹម ចែម និងស្នើថា ការខ្វែងយោបល់គ្នាមួយចំនួនដែលទាក់ទិននឹងការកោះហៅ និងការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម គួរត្រូវបានបញ្ជូនទៅកាន់អង្គបុរេជំនុំជម្រះ" ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៤ និងជូនដំណឹងនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ A122/1"។

2. នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ សហមេធាវីបានដាក់ញត្តិជូនការិយាល័យសហចៅក្រមស៊ើបអង្កេតស្នើសុំឲ្យបំភ្លឺអំពីការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតលើវិធាន ៧២ នៃវិធានផ្ទៃក្នុង និងជំហររបស់សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នាដែលពួកគាត់បានដាក់ចូលក្នុងសំណុំឯកសារក្នុងសំណុំរឿង ០០៤[4]។

3. នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកោះហៅ អ៊ឹម ចែម ឲ្យបង្ហាញខ្លួនលើកដំបូងនៅកាលបរិច្ឆេទនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ វេលាម៉ោង ៤ រសៀល ("ដីកាកោះ អ៊ឹម ចែម")[5]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានកោះហៅសហមេធាវីឲ្យមកចូលរួមការបង្ហាញខ្លួនលើកដំបូងរបស់ អ៊ឹម ចែម ផងដែរ ("ដីកាកោះមេធាវី")[6]។

4. នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវីបានបញ្ជូនលិខិតមួយច្បាប់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេតដោយបានលើកឡើងថា សហមេធាវីពុំពិចារណាឃើញថា ដីកាកោះ អ៊ឹម ចែម បានប្រគល់ឲ្យត្រឹមត្រូវទេ ដោយហេតុថា ដីកាកោះនេះបានចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ឯង[7]។ នៅក្នុងថ្ងៃខែឆ្នាំដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានឆ្លើយតបថា អនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតអន្តរជាតិអាចចេញដីកាកោះ អ៊ឹម ចែម ឲ្យបង្ហាញខ្លួនលើកដំបូងដោយសុពលភាពតែម្នាក់ឯងបានដូចបានលើកឡើងនាពេលមុនដោយអង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ និងដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងលិខិតចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤[8]។

---

[4] ញត្តិរបស់ អ៊ឹម ចែម ស្នើសុំឲ្យមានការបកស្រាយបំភ្លឺទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D204។

[5] ដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ និងជូនដំណឹងទៅ អ៊ឹម ចែម នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ A150។

[6] ដីកាកោះមេធាវី ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ និងជូនដំណឹងទៅ អ៊ឹម ចែម នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ A151។

[7] លិខិតមកពីសហមេធាវីផ្ញើជូនសហចៅក្រមស៊ើបអង្កេត កម្មវត្ថុ៖ "ចម្លើយតបទៅនឹងដីកាកោះអញ្ជើញយើងខ្ញុំ ដើម្បីចូលរួមនៅក្នុងការបង្ហាញខ្លួនបឋមរបស់អ្នកស្រី អ៊ឹម ចែម នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤" ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A151/2។

[8] លិខិតមកពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្ញើជូនសហមេធាវី ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A122/5។

5. នៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវីបានដាក់ពាក្យសុំបន្ទាន់មួយជូនការិយាល័យសហចៅក្រមស៊ើបអង្កេតស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះ អ៊ឹម ចែម និងដីកាកោះមេធាវីទៅអង្គបុរេជំនុំជម្រះ ("ពាក្យសុំមោឃភាព")[9]។ សហមេធាវីបានស្នើសុំឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេតព្យួរដីកាកោះ "រង់ចាំរហូតដល់ពេលសហចៅក្រមស៊ើបអង្កេតបញ្ជូនសំណើសុំមោឃភាព [ដីកាកោះ] ទៅអង្គបុរេជំនុំជម្រះសម្រេចជាមុនសិន និងរង់ចាំសហចៅក្រមស៊ើបអង្កេតបញ្ជាក់បំភ្លឺលើការខ្វែងយោបល់គ្នាលើកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអ្នកស្រី អ៊ឹម ចែម ជាមុនសិន"[10]។ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "បានបញ្ជាក់យ៉ាងច្បាស់ចំពោះមេធាវីការពារក្តីនៅក្នុងកិច្ចប្រជុំថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១៤ ថា គាត់នឹងបដិសេធសំណើនេះ"[11]។

6. នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ វេលាម៉ោង ៨:១៥ នាទី សហមេធាវីបានដាក់សំណើសុំព្យួរ ហើយបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ "ព្យួរការអនុវត្តដីកាកោះហៅអ្នកស្រី អ៊ឹម ចែម រហូតដល់ពេលដែលមានសេចក្តីសម្រេចជាស្ថាពរ ដោយអង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធលើសំណើសុំមោឃភាពរបស់អ្នកស្រី"[12]។ សហមេធាវីលើកឡើងថា ពួកគេ "ជំទាស់ទៅនឹងសុពលភាពនៃដីកាកោះហៅ ដោយផ្អែកលើមូលដ្ឋានថា ដីកានេះត្រូវចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ*តែម្នាក់ឯង* ដោយគ្មានការឯកភាពពីសហចៅក្រមស៊ើបអង្កេតជាតិទេ"[13]។ សហមេធាវីសន្និដ្ឋានថា សំណើសុំព្យួរនេះ "ត្រូវធ្វើឡើងចាំបាច់ ព្រោះថាសុពលភាពនៃដីកាកោះហៅនេះ ចាំបាច់ត្រូវមានការសម្រេចមុនពេលដែលអ្នកស្រី អ៊ឹម ចែម មកបង្ហាញខ្លួនជាលើកដំបូង ហើយធ្វើការចោទប្រកាន់អ្នកស្រីនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤"[14]។ ពិសេសជាង

---

[9] ពាក្យសុំបន្ទាន់របស់ អ៊ឹម ចែម ស្នើសុំបញ្ជូនសំណើសុំមោឃភាពដីកាកោះរបស់គាត់ និងរបស់សហមេធាវី ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ ទៅអង្គបុរេជំនុំជម្រះ។ ពាក្យសុំនេះបានដាក់ដោយសហមេធាវីនៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១៤ និងបានដាក់ចូលទៅក្នុងសំណុំរឿង និងជូនដំណឹងទៅអង្គបុរេជំនុំជម្រះនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D207។

[10] ពាក្យសុំមោឃភាព ផ្នែកទី V។

[11] សំណើសុំព្យួរ សេចក្តីផ្តើម។

[12] សំណើសុំព្យួរ ផ្នែកទី IV។

[13] សំណើសុំព្យួរ សេចក្តីផ្តើម។

[14] សំណើសុំព្យួរ សេចក្តីផ្តើម។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

នេះ សហមេធាវីលើកឡើងថា ពួកគេនឹងប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើពាក្យសុំមោឃភាព ក្រោយពេលចេញសេចក្តីសម្រេចនេះ ហើយបណ្តឹងឧទ្ធរណ៍នេះ នឹង "បានត្រឹមតែជាទ្រឹស្តី" ប្រសិនបើដីកាកោះត្រូវបានអនុវត្តនៅត្រឹមពេលនោះ[15]។ សហមេធាវីផ្តល់ទឡ្ហីករណ៍តវ៉ាបន្ថែមទៀតថា អ៊ឹម ចែម នឹងទទួលរងព្យសនកម្មមិនអាចជួសជុលបាន ប្រសិនបើគាត់បង្ហាញខ្លួនលើកដំបូង ដែលអាចចាត់ទុកជាមោឃៈនាពេលក្រោយនោះ[16]។ នៅក្នុងកាលៈទេសៈទាំងនេះ សហមេធាវីលើកឡើងថា អង្គបុរេជំនុំជម្រះ ដែលនៅទីបំផុតនឹងទទួលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធពាក្យសុំមោឃភាពនោះ គឺមាន "យុត្តាធិការឥស្សរចិត្ត" ក្នុងការព្យួរការអនុវត្តដីកាកោះនេះ[17]។ សំណើសុំព្យួរបានដាក់ជាភាសាអង់គ្លេសតែមួយភាសាគត់ ហើយបានដាក់ជូន*សហចៅក្រមស៊ើបអង្កេតអន្តរជាតិ*តែម្ខាង ដោយសារដីកាកោះនេះត្រូវបានធ្វើចំណាត់ប្រភេទ "សម្ងាត់បំផុត" ហើយភាគី ឬ អ្នកចូលរួមក្នុងកិច្ចដំណើរការនីតិវិធីមិនមានលទ្ធភាពចូលមើលបាននោះទេ។

7. នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ដោយសារស្ថានភាពបន្ទាន់ អង្គបុរេជំនុំជម្រះបានចេញផ្នែកសម្រេចសេចក្តីនៃសំណើសុំព្យួរ ដែលបានសរសេររៀបរាប់ដូចខាងក្រោម៖

"**អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ**

**ច្រានចោល**សំណើសុំព្យួរ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា"។

8. ដូចបានប្រកាសកាលពីថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ អង្គបុរេជំនុំជម្រះចេញសំអាងហេតុសម្រាប់សេចក្តីសម្រេចនាពេលនេះ។

## សំអាងហេតុសម្រាប់សេចក្តីសម្រេចដែលបានចេញកាលពីថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤

9. ពីដំបូង អង្គបុរេជំនុំជម្រះជូនដំណឹងថា អង្គបុរេជំនុំជម្រះបានសម្រេចពិចារណាសំណើសុំព្យួរនេះជាករណីពិសេស ទោះបីជាសំណើសុំព្យួរនេះបានដាក់តែជាភាសាអង់គ្លេសក៏ដោយ ដើម្បីជៀសវាងស្ថានភាពពុំប្រាកដប្រជា ពាក់ព័ន្ធនឹងដីកាកោះដែលត្រូវអនុវត្តនៅក្នុងថ្ងៃដែលសំណើសុំព្យួរនេះ

[15] សំណើសុំព្យួរ សេចក្តីផ្តើម។

[16] សំណើសុំព្យួរ កថាខណ្ឌ ១៥។

[17] សំណើសុំព្យួរ កថាខណ្ឌ ២។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

បានដាក់។ អង្គបុរេជំនុំជម្រះបានប្រើប្រាស់ធនធានភាសាផ្ទៃក្នុង ដើម្បីឈានដល់ការសម្រេចសេចក្តីនេះ។

10. អង្គបុរេជំនុំជម្រះបានរកឃើញនាពេលមុនរួចហើយថា ដោយសារពុំមានបទប្បញ្ញត្តិនៅក្នុងក្រមច្បាប់នៃ អ.វ.ត.ក ឬ ច្បាប់កម្ពុជា អង្គបុរេជំនុំជម្រះអាចពន្យារដីកាដែលចេញដោយសហចៅក្រមស៊ើបអង្កេត(ទាំងពីរ)បានដោយប្រើប្រាស់ "អន្ទានុសិទ្ធិឥស្សរចិត្ត" ដើម្បីជៀសវាងកុំឱ្យសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍គ្មានប្រសិទ្ធភាព ឬ ដើម្បីរក្សាភាពយុត្តិធម៌នៃដំណើរការធ្វើបណ្តឹងឧទ្ធរណ៍[18]។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ឡើងវិញថា ដើម្បីអាចឱ្យអង្គបុរេជំនុំជម្រះយល់ព្រមតាមសំណើសុំពន្យារ ភាគីត្រូវបង្ហាញភស្តុតាងជូនអង្គបុរេជំនុំជម្រះថា ការអនុវត្តកិច្ច ឬ ដីកាណាមួយ ដែលម្ចាស់បណ្តឹងឧទ្ធរណ៍ស្នើសុំពន្យារ "នឹងនាំឱ្យមានផលវិបាកដោយផ្ទាល់ទៅលើកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ដែលខ្លួនបានទទួល"[19]។ ម្យ៉ាងវិញទៀត ដើម្បីអាចឱ្យអង្គបុរេជំនុំជម្រះយល់ព្រមតាមសំណើសុំពន្យារ សំណើសុំពន្យារត្រូវបំពេញតាមលក្ខខណ្ឌចំនួនបីដូចខាងក្រោម៖

"ក. មានមូលហេតុសមស្របសម្រាប់សំណើសុំពន្យារ។

ខ. រយៈពេលនៃសំណើសុំពន្យារមានភាពសមស្រប និង

គ. បណ្តឹងឧទ្ធរណ៍មានលទ្ធភាពសមហេតុផលអាចទទួលជោគជ័យលើអង្គសេចក្តី"[20]។

---

[18] សំណុំរឿង ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៣") (អ.ប.ជ ០៣) ដីកាសម្រេចពន្យារការអនុវត្ត "ដីកាសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣" ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ D14/1/2។ សំណុំរឿង ០០៣ (អ.ប.ជ ១១) សេចក្តីសម្រេចលើសំណើសុំឱ្យមានវិធានការបណ្តោះអាសន្ន" ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D56/19/8 កថាខណ្ឌ ១៥។ *សូមមើល* ផងដែរ សំណុំរឿង ០០៣ (អ.ប.ជ ១១) សេចក្តីសម្រេចលើសំណើសុំឱ្យផ្អាកការអនុវត្តដីកាសម្រេចឱ្យតែងតាំងមេធាវីបណ្តោះអាសន្នសំរាប់ [កោសលុប]" ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D56/19/14 ("សេចក្តីសម្រេចលើសំណើសុំផ្អាកការតែងតាំង") កថាខណ្ឌ ១៦។ សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (២៦) សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ E284/2/1/2 កថាខណ្ឌ ១២។

[19] សេចក្តីសម្រេចលើសំណើសុំផ្អាកការតែងតាំង កថាខណ្ឌ ១៦។

[20] សាលាក្តីពិសេសសម្រាប់ប្រទេសលីបង់ សំណុំរឿង CH/AC/2011/01 ដីកាសម្រេចលើសំណើបន្ទាន់របស់អយ្យការសុំអានុភាពពន្យារដើម្បីរង់ចាំបណ្តឹងឧទ្ធរណ៍ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៨។ *សូមមើល ផងដែរ* កថាខណ្ឌ ១១ ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍គូសបញ្ជាក់ថា "បណ្តឹងឧទ្ធរណ៍នេះត្រូវមានឱកាសទទួលបានជោគជ័យយ៉ាងសមហេតុសមផលដោយខ្លួនវា" និងសំណើសុំពន្យារពុំត្រូវ "ភាគីដែលបានដាក់សំណើសុំយកមកធ្វើជាយុទ្ធវិធីពន្យារពេលនោះឡើយ"។

01008521



11. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បច្ចុប្បន្ន អង្គបុរេជំនុំជម្រះពុំទាន់ទទួលបានពាក្យសុំមោឃភាពពាក់ព័ន្ធនឹងដីកាកោះនោះទេ។ ប៉ុន្តែ សំណើសុំព្យួរបានផ្អែកមូលដ្ឋានលើពាក្យសុំមួយនាពេលខាងមុខ ដែលសហមេធាវីមានបំណងដាក់ជូនអង្គបុរេជំនុំជម្រះ នៅពេលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីសម្រេច ពាក់ព័ន្ធនឹងពាក្យសុំរបស់សហមេធាវីស្នើសុំបញ្ជូនពាក្យសុំមោឃភាពទៅអង្គបុរេជំនុំជម្រះ។ ក្នុងករណីនេះ អង្គបុរេជំនុំជម្រះសូមរំលឹកឡើងវិញថា វិធានផ្ទៃក្នុងតម្រូវឱ្យដាក់ពាក្យសុំមោឃភាពទៅសហចៅក្រមស៊ើបអង្កេតជាមុនសិន ដែលត្រូវសម្រេចថាតើគួរ ឬ មិនគួរបញ្ជូនមកអង្គបុរេជំនុំជម្រះ[21]។ អង្គបុរេជំនុំជម្រះទទួលស្គាល់ថា សហមេធាវីមិនមានលទ្ធភាពបញ្ជូនមកអង្គបុរេជំនុំជម្រះនូវពាក្យសុំមោឃភាព នៅពេលដែលពួកគេបានដាក់សំណើសុំព្យួរនេះកាលពីថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ នោះទេ ដោយហេតុថា សហចៅក្រមស៊ើបអង្កេតពុំទាន់បានសម្រេចថាតើគួរ ឬ ពុំគួរបញ្ជូនពាក្យសុំបែបនេះមកអង្គបុរេជំនុំជម្រះនៅឡើយ។ ដូច្នេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ជាជាងស្នើសុំមោឃភាពដីកាកោះភ្លាមៗក្រោយពីបានជូនដំណឹងនៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ សហមេធាវីបែរជាជ្រើសរើសបញ្ជូនលិខិតមួយច្បាប់ទៅសហចៅក្រមស៊ើបអង្កេតអន្តរជាតិយ៉ាងចម្លែក ដោយប្រកាសអំពីគោលបំណងរបស់ពួកគេមិនចូលរួមក្នុងការបង្ហាញខ្លួនលើកដំបូង និងដោយបានលើកឡើងថា ពួកគេពិចារណាឃើញថា ដីកាកោះពុំមានសុពលភាព។ ដូច្នេះ ពាក្យសុំមោឃភាពរបស់ពួកគេបានដាក់នៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១៤ ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានត្រឹមទុកពេលវេលាបន្តិចបន្តួចសម្រាប់ឱ្យសហចៅក្រមស៊ើបអង្កេត និង ចុងក្រោយ អង្គបុរេជំនុំជម្រះដោះស្រាយលើពាក្យសុំនេះ នៅមុនកាលបរិច្ឆេទកំណត់សម្រាប់ការបង្ហាញខ្លួនលើកដំបូង។ ទោះបីជាពុំអាចបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេត(ទាំងពីរ)អាចទំនងចេញសេចក្តីសម្រេចលើពាក្យសុំមោឃភាពនៅមុនថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ដែលគួរតែបានដាក់នៅមុនថ្ងៃនេះក៏ដោយ ក៏យ៉ាងហោចណាស់ គេក៏អាចសន្និដ្ឋានបានថា ក្នុងឱកាសដំបូង សហមេធាវីពុំបានប្រើប្រាស់យន្តការនីតិវិធីសមស្រប ដើម្បីតវ៉ាសុពលភាពនៃដីកាកោះនេះទេ។ ជាពិសេស ការបញ្ជូនលិខិតមួយច្បាប់ជូនទៅសហចៅក្រមស៊ើបអង្កេតអន្តរជាតិកាលពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ ពុំមែនជាការដាក់ជាផ្លូវការនូវបញ្ហាណាមួយនៅចំពោះមុខចៅក្រម ឬ នៅចំពោះមុខតុលាការដើម្បី

---

[21] សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០២") (អ.ប.ជ ០៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះការបដិសេធពាក្យសុំមោឃភាព ឯកសារ D55/I/8 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ កថាខណ្ឌ ១៦, ២១-២៣។

ពិចារណានោះឡើយ។ នៅក្នុងកាលៈទេសៈបច្ចុប្បន្ន គេនៅតែសង្ស័យថាតើអង្គបុរេជំនុំជម្រះនឹងមានយុត្តាធិការព្យួរការអនុវត្តដីកាកោះដែរឬក៏អត់។

12. ទោះបីជាយ៉ាងនេះក៏ដោយ ដោយសារផលប្រយោជន៍ដែលបានលើកឡើង និងដើម្បីជៀសវាងករណីដែលថា អ៊ឹម ចែម ទទួលរងផលប៉ះពាល់ដោយសារលទ្ធផលនៃចំណាត់ការដែលធ្វើឡើងដោយសហមេធាវីរបស់គាត់ អង្គបុរេជំនុំជម្រះបានពិនិត្យមើលថាតើគោលបំណងដែលសហមេធាវីបានប្រកាសឡើង ដើម្បីតវ៉ាលើសុពលភាពនៃដីកាកោះនៅចំពោះមុខអង្គបុរេជំនុំជម្រះ តាមរយៈពាក្យសុំមោឃភាពតម្រូវឱ្យអង្គបុរេជំនុំជម្រះព្យួរការអនុវត្តដីកាកោះដែរឬទេ។ អង្គបុរេជំនុំជម្រះយល់ឃើញថា បើទោះក្នុងករណីអង្គបុរេជំនុំជម្រះ មានយុត្តាធិការបង្គាប់ឱ្យព្យួរមែនក៏ដោយ ការព្យួរនេះពុំមានភាពចាំបាច់នោះទេនៅក្នុងកាលៈទេសៈបច្ចុប្បន្ន ដោយសារហេតុផលចំនួនពីរ។

13. ហេតុផលទីមួយ សហមេធាវីពុំបានបង្ហាញភស្តុតាងថា អ៊ឹម ចែម នឹងទទួលរងព្យសនកម្ម "ពុំអាចជួសជុលបាន" ប្រសិនបើគាត់បង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេតក្នុងគោលបំណងទទួលការជូនដំណឹងអំពីបទចោទប្រឆាំងនឹងគាត់ និងប្រសិនបើដីកាកោះត្រូវបានចាត់ទុកជាមោឃៈនាកាលក្រោយមកនោះ។ អ៊ឹម ចែម ពុំមានកាតព្វកិច្ចត្រូវធ្វើសេចក្តីថ្លែងការណ៍ណាមួយនៅក្នុងអំឡុងពេលនៃការបង្ហាញខ្លួនលើកដំបូងនោះឡើយ ហើយប្រសិនបើដីកាកោះ និង/ឬ សេចក្តីសម្រេចស្តីពីការចោទប្រកាន់ត្រូវបានចាត់ទុកជាមោឃៈនាពេលក្រោយមកនោះ ដីកាកោះ និង/ឬ សេចក្តីសម្រេចនេះនឹងត្រូវបានចាត់ទុកជាមោឃៈ និងពុំមានអានុភាព ហាក់ដូចជាដីកាកោះ និង/ឬ សេចក្តីសម្រេចនេះពុំដែលធ្លាប់មានអត្ថិភាពពីមុនមក។ បន្ទាប់មក អ៊ឹម ចែម នឹងស្ថិតនៅក្នុងស្ថានភាពដូចគ្នានឹងស្ថានភាពពីមុន។

14. ហេតុផលទីពីរ អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានដែលបានលើកឡើងដោយសហមេធាវីយកមកតវ៉ាលើសុពលភាពនៃដីកាកោះ *ពោលគឺ* សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានអំណាចចេញដីកាកោះតែម្នាក់ឯងនោះ *យោងតាមភស្តុតាងបឋម* ពុំមានមូលដ្ឋាន។ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា ពួកគាត់បានចុះបញ្ជីការខ្វែងយោបល់គ្នាពាក់ព័ន្ធនឹងដីកាកោះ ហើយរយៈពេល ៣០ ថ្ងៃ សម្រាប់នាំយកការខ្វែងយោបល់គ្នានេះមកចំពោះមុខអង្គបុរេជំនុំជម្រះបានកន្លងផុត។ នៅក្នុងកាលៈទេសៈទាំងនេះ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបង្កើតឱ្យមាន អ.វ.ត.ក ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង បានបង្ហាញយ៉ាងច្បាស់ថា

សហចៅក្រមស៊ើបអង្កេតអន្តរជាតិអាចចេញដីកាកោះដោយមានសុពលភាពតែម្នាក់ឯងបាន[22]។ ម្យ៉ាងវិញទៀត អង្គបុរេជំនុំជម្រះបានបញ្ជាក់នាពេលមុនរួចហើយថា សហព្រះរាជអាជ្ញាម្នាក់ ឬ សហចៅក្រមស៊ើបអង្កេតម្នាក់អាចបំពេញកិច្ចតែម្នាក់ឯងបាន នៅពេលការខ្វែងយោបល់គ្នាបានចុះបញ្ជីរួចរាល់នៅក្នុងការិយាល័យសហព្រះរាជអាជ្ញា ឬ ការិយាល័យសហចៅក្រមស៊ើបអង្កេតតាមករណីសមស្រប និងរយៈពេលនាំយកការខ្វែងយោបល់គ្នា មកចំពោះមុខអង្គបុរេជំនុំជម្រះបានកន្លងផុត[23]។ វាជាការមិនសមស្របឡើយប្រសិនបើអង្គបុរេជំនុំជម្រះពិចារណាឲ្យការអនុវត្តដីកាកោះដោយផ្អែកលើពាក្យសុំនាពេលចុងក្រោយ ដែលទំនងជានឹងធ្វើការតវ៉ាលើវិធានមួយដែលចែងយ៉ាងច្បាស់នៅក្នុងបទប្បញ្ញត្តិនៃកម្រងច្បាប់ អ.វ.ត.ក និងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ។

ភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤

ប្រធានអង្គបុរេជំនុំជម្រះ

ប្រាក់ គឹមសាន

---

[22] មាត្រា ៥(៤) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ មាត្រា ២៣ ថ្មី (២) នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤។ វិធាន ៧២(២) និង (៣) នៃវិធានផ្ទៃក្នុង។

[23] ការខ្វែងយោបល់គ្នា ០០១/១៨-១១-២០០៨-អ.វ.ត.ក/អ.ប.ជ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ កថាខណ្ឌ ១៦ និង ២៧។ សំណុំរឿង ០០២ (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៧៤-២៧៦។